អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន
# ដីកាសម្រេចផ្ទាល់មាត់ហាមមិនឲ្យផ្សព្វផ្សាយរូបថត និងរូបភាពរបស់សាក្សីជាសាធារណៈ

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សូមជម្រាបជូនដល់តំណាងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ថា ថ្ងៃនេះ លោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង បានចេញដីកាសម្រេចផ្ទាល់មាត់មួយដែលមានខ្លឹមសារដូចខាងក្រោមនេះ៖

"អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្តល់វិធានការការពារដល់សាក្សីមានរហស្សនាម 2-TCW-944 ដែលរួមមាន ការហាមមិនឲ្យបញ្ចេញអាសយដ្ឋាន និងរូបភាពសាក្សីនេះទៅដល់សាធារណជន។ នៅក្នុងសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះ ប្រព័ន្ធផ្សព្វផ្សាយត្រូវបានបង្គាប់មិនឲ្យផ្សព្វផ្សាយរូបថត ឬ រូបភាពរបស់សាក្សីរូបនេះ បើទោះបីរូបភាពពីមុនៗក៏ដោយ"។

ដីកានេះមានន័យបន្ថែមផងដែរថា ទោះបីជារូបថត ឬ រូបភាពសាក្សីដែលបានថតនៅខាងក្រៅសាលសវនាការ ឬ បានថតនៅទីណាក៏ដោយ ព្រមទាំងរូបភាពចាស់ៗ ក៏ត្រូវបានហាមមិនឲ្យផ្សព្វផ្សាយដែរ ។ ការហាមមិនឲ្យផ្សព្វផ្សាយរូបភាព ឬ រូបថតនេះមិនរួមបញ្ចូលរូបភាពបំផ្លែង (រូបមិនច្បាស់) ដែលផ្តល់ឲ្យដោយ អ.វ.ត.ក នោះឡើយ។

វីដេអូស្តីពីការប្រកាសដីកាផ្ទាល់មាត់នេះអាចរកបាននៅលើគេហទំព័ររបស់ អ.វ.ត.ក តាមអាសយដ្ឋានខាងក្រោម៖
http://www.eccc.gov.kh/articles/31733

***សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖***

**លោក ឡាស អូលសិន**
មន្ត្រីច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh